# រឿងទី៧៖ សូដុម និងកូម៉ូរ៉ា

**ខគម្ពីរ៖ លោកុប្បត្តិ១៩៖២៩**

នៅពេលព្រះជាម្ចាស់រំលាយក្រុងទាំងប៉ុន្មាន នៅតំបន់វាលរាបនោះ ព្រះអង្គបាននឹកគិតដល់លោកអប្រាហាំ គឺព្រះអង្គបានប្រោសលោកឡុតឲ្យរួចផុតពីមហន្តរាយ ក្នុងពេលព្រះអង្គរំលាយក្រុងដែលលោកឡុតរស់នៅនោះ។

កាលពីដើម មនុស្សដែលរស់នៅក្រុងសូដុម និងក្រុងកូម៉ូរ៉ា បានប្រព្រឹត្តអំពើបាបយ៉ាងច្រើននៅចំពោះព្រះជាម្ចាស់។
ដោយព្រោះអំពើបាបរបស់ពួកគេកាន់តែធំទៅៗដូច្នេះ ព្រះជាម្ចាស់ក៏មានបន្ទូលប្រាប់ទៅអប្រាហាំថាទ្រង់មានផែនការដុតបំផ្លាញក្រុងទាំងពីរនេះដោយភ្លើង។
ពេលអប្រាហាំលឺអ្វីដែលព្រះជាម្ចាស់មានបន្ទូលហើយ គាត់ព្រួយបារម្ភពីឡុតជាក្មួយគាត់ ដែលកំពុងរស់នៅក្រុងសូដុម គាត់បានអធិស្ឋានទូលអង្វរដល់ព្រះជាម្ចាស់ថា៖
«ព្រះជាម្ចាស់អើយ ប្រសិនបើក្នុងក្រុងសូដុមនិងក្រុងកូម៉ូរ៉ាមានមនុស្សសុចរិតចំនួនដប់នាក់រស់នៅទីនោះ តើទ្រង់អាច អត់ទោសដល់ក្រុងសូដុម និងកូម៉ូរ៉ាដោយយល់ដល់ពួកសុចរិតទាំងនោះបានដែរឬទេ»។ ព្រះជាម្ចាស់មានបន្ទូលឆ្លើយទៅថា៖ «ប្រសិនបើក្នុងក្រុងសូដុមនិងកូម៉ូរ៉ាមានមនុស្សសុចរិតតែដប់នាក់មែននោះ យើងនឹងអត់ទោសឱ្យក្រុងនោះ»។





ប៉ុន្តែ នៅក្នុងក្រុងសូដុម គ្មានមនុស្សសុចរិតដប់នាក់នោះទេ។
ដ្បិតព្រះជាម្ចាស់បានសម្រេចព្រះទ័យថានឹងដាក់ទោសក្រុងសូដុមក៏ពិតមែន ប៉ុន្តែ ទ្រង់ថានឹងជួយសង្គ្រោះគ្រួសារឡុត។
ព្រះជាម្ចាស់បានបញ្ជូនពួកទេវតាឱ្យទៅនិយាយជាមួយឡុតថា៖
«ដោយព្រោះទីក្រុងមួយនេះ បានប្រព្រឹត្តអំពើបាបយ៉ាងធំចំពោះព្រះជាម្ចាស់ ដូច្នេះ ព្រះជាម្ចាស់បានបញ្ជូនពួកយើងឱ្យមកដើម្បីបំផ្លាញទីក្រុងនេះ។ ចូរអ្នកនាំគ្រួសារអ្នកចេញពីនេះ ហើយដាច់ខាតកុំងាកមើលក្រោយ កុំឈប់នៅតំបន់វាលរាបឱ្យសោះ ត្រូវរត់ទៅតំបន់ភ្នំវិញ»។
ព្រះជាម្ចាស់ ទ្រង់ចង់បំផ្លាញមនុស្សទាំងអស់ដែលរស់នៅក្នុងក្រុងសូដុម ប៉ុន្តែ ទ្រង់បានសង្គ្រោះឡុត និងគ្រួសារ ដោយយល់ដល់អប្រាហាំ។
ពេលឡុតទៅដល់ក្រុងសូអារ ព្រះអាទិត្យក៏រះឡើង។
ព្រះជាម្ចាស់បង្អុរភ្លៀងជាស្ពាន់ធ័រ និងភ្លើងចុះពីមេឃ ធ្លាក់គ្រប់លើក្រុងសូដុម និងក្រុងកូម៉ូរ៉ា។
គ្រប់មនុស្ស សត្វ និងរុក្ខជាតិទាំងអស់ដែលមាននៅក្នុងក្រុងនោះ គឺត្រូវឆេះស្លាប់នៅក្នុងភ្លើងទាំងអស់។
ព្រះជាម្ចាស់បានប្រាប់តាមពួកទេវតាថា កុំឱ្យពួកគេងាកក្រោយមើលក្រុងសូដុមដែលកំពុងឆេះនោះឱ្យសោះ ប៉ុន្តែ ភរិយារបស់ឡុត បានភ្លេចអ្វីដែលទេវតាបានប្រាប់ គាត់បានងាកមើលក្រោយ គាត់ក៏ក្លាយជារូបចម្លាក់អំបិលនៅទីនោះទៅ។

**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។



a. ហេតុអ្វីបានជាក្រុងសូដុម និងក្រុងកូម៉ូរ៉ាត្រូវបំផ្លាញ?

---

b. ព្រះជាម្ចាស់បានសង្គ្រោះលោកឡុត ដោយសារទ្រង់ស្រឡាញ់អ្នកណា?

---

c. តើអ្នកណាដែលងាកមើលក្រោយ ហើយមានរឿងអ្វីកើតឡើងចំពោះគាត់?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ១៩:២៩)

> ព្រះអង្គបាននឹកគិតដល់លោកអប្រាហាំ គឺព្រះអង្គបានប្រោសលោកឡុតឲ្យរួចផុតពីមហន្តរាយ

## សកម្មភាពទី២

លោកឡុត និងក្រុមគ្រួសារត្រូវតែរត់គេច។ តើពួកគេត្រូវជ្រើសរើសផ្លូវណា?
សូមជ្រើសរើសលេខ ១-៧ ដែលអាចនាំផ្លូវឱ្យទៅដល់តំបន់សុវត្ថិភាព។ បន្តទៅមុខពីឆ្វេងទៅស្តាំ ហើយនៅពេលជួបបន្ទាត់បញ្ឈរ សូមផ្លាស់ទីឡើងលើ ឬចុះក្រោម រហូតដល់ទៅដល់តំបន់គេចខ្លួន។

